01034447

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

លេខ/No: D192/1/1/2 និង ~~D186/3/1/2~~

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស **(អបជ ០៦)** និង(~~អបជ ១០~~)

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន** **ប្រធាន**
**ចៅក្រម** Rowan DOWNING
**ចៅក្រម នីយ ថុល**
**ចៅក្រម** Chang-Ho CHUNG
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 20 / 11 / 2014
ម៉ោង (Time/Heure): 13:35
មន្ត្រីទទួលបន្ទុកសំណុំរឿង Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ (សំណៅកោសល្លុប)**

**ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធសំណើរបស់គាត់សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ**

---

**<u>សហព្រះរាជអាជ្ញា:</u>**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍:</u>**

សូ មូស្សេន្នី
Susana TOMANOVIC

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

| | |
|---|---|
| ជេត វណ្ណលី | Herve DIAKIESE |
| ហុង គីមសួន | Ferdinand DJAMMEN- NZEPA |
| គីម ម៉េងឃី | Nicole DUMAS |
| ឡោ ជុនធី | Isabelle DURAND |
| សំ សុគង់ | Françoise GAUTRY |
| ស៊ិន ស៊ុវ៉ន | Martine JACQUIN |
| ទី ស្រីនណា | Emmanuel JACOMY |
| វ៉េន ពៅ | Christine MARTINEAU |
| Annie DELAHAIE | Barnabe NEKUI |
| Laure DESFORGES | Lyma NGUYEN |
| | Beini YE |

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួលបណ្ដឹងឧទ្ធរណ៍ចំនួនពីររបស់សហមេធាវីរបស់ [redacted] ("ម្ចាស់បណ្ដឹងឧទ្ធរណ៍") ប្រឆាំងនឹងដីកាចំនួនពីរដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញ នៅក្នុងដំណើរការពិចារណាទៅលើសំណើសុំចូលពិនិត្យមើលសំណុំរឿង និងសុំសិទ្ធិចូលរួមក្នុងកិច្ចស៊ើបសួរ។ បណ្ដឹងឧទ្ធរណ៍ទីមួយគឺ "បណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចបដិសេធរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើបន្ទាន់របស់គាត់ដែលសុំឱ្យមានដំណោះស្រាយផ្អែកលើព័ត៌មានថ្មី" ដែលសហមេធាវីការពារក្ដីរបស់ [redacted] បានដាក់នៅថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ("បណ្ដឹងឧទ្ធរណ៍ទីមួយ")[1]។ បណ្ដឹងឧទ្ធរណ៍ទីពីរគឺ "បណ្ដឹងឧទ្ធរណ៍របស់ [redacted] ចំពោះដីកាសម្រេចលើសំណើជាបន្ទាន់របស់គាត់ ដែលសុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ" ដែលត្រូវបានដាក់នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ ("បណ្ដឹងឧទ្ធរណ៍ទីពីរ")[2]។ ដូចមានបង្ហាញយ៉ាងលម្អិតនៅក្នុងផ្នែកដែលមានចំណងជើងថា "ប្រវត្តិនីតិវិធី" និង "សារណាលើបណ្ដឹងឧទ្ធរណ៍" នៃការពិចារណាទាំងនេះ បណ្ដឹងឧទ្ធរណ៍ទាំងពីរបានជំទាស់ទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដោយដីកាសម្រេចនីមួយៗបានបដិសេធទៅលើសិទ្ធិដែលត្រូវបានស្នើឡើង ដោយផ្អែកលើមូលដ្ឋានដែលថា ក្នុងនាមជាជនសង្ស័យ ម្ចាស់បណ្ដឹងឧទ្ធរណ៍មិនមែនជាភាគីនៃកិច្ចដំណើរការនីតិវិធីនោះទេ ដូច្នេះ ច្បាប់ជាធរមានមិនបានផ្ដល់ឱ្យគាត់នូវសិទ្ធិដែលត្រូវបានស្នើសុំនោះឡើយ។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា បើទោះបីជាដីកាសម្រេចទាំងពីរត្រូវបានចេញនៅពេលផ្សេងៗគ្នាក៏ដោយ ដីកាសម្រេចទាំងពីររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលរងការជំទាស់ ទាក់ទងទៅនឹងដំណើរការតែមួយ និងទៅលើបញ្ហាចម្បងដូចគ្នា ដែលសហមេធាវីការពារក្ដីរបស់ [redacted] បានលើកឡើង ហើយដីកាសម្រេចទាំងនេះបានបដិសេធលើសំណើពាក់ព័ន្ធផ្សេងទៀត ដោយផ្អែកលើមូលដ្ឋានប្រហាក់ប្រហែលគ្នា។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះត្រូវដោះស្រាយទៅលើបណ្ដឹងឧទ្ធរណ៍នេះជាមួយគ្នា។

## I. **ប្រវត្តិនីតិវិធី**

1. នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ចាប់ផ្ដើមការស៊ើបអង្កេតទៅលើ

[1] បណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចបដិសេធរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណុំបន្ទាន់របស់គាត់ដែលសុំឱ្យមានដំណោះស្រាយផ្អែកលើព័ត៌មានថ្មី, ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ D192/1/1/1។

[2] បណ្ដឹងឧទ្ធរណ៍របស់ [redacted] ចំពោះដីកាសម្រេចលើសំណើជាបន្ទាន់របស់គាត់ ដែលសុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ, ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤, ឯកសារ D186/3/1/1, ("បណ្ដឹងឧទ្ធរណ៍ទីពីរ")។

ក្នុងចំណោមនោះ ឧក្រិដ្ឋកម្មដែលម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានចោទប្រកាន់ថាត្រូវទទួលខុសត្រូវ[3]។ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ និងថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួនពីរ ដោយចោទប្រកាន់ទៅលើឧក្រិដ្ឋកម្មដទៃទៀត ដែលម្ចាស់បណ្តឹងឧទ្ធរណ៍ ក៏អាចត្រូវទទួលខុសត្រូវដែរ[4]។

2. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានចេញឯកសារដែលមានចំណងជើងថា ការជូនដំណឹងពីសិទ្ធិរបស់ជនសង្ស័យ ("ការជូនដំណឹងរបស់ ស.ច.ស.អ.ប") ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានជូនដំណឹងដល់ ម្ចាស់បណ្តឹងឧទ្ធរណ៍ថា គាត់ត្រូវបានជាប់ឈ្មោះថា ជាជនសង្ស័យម្នាក់នៅក្នុងកិច្ចស៊ើបអង្កេតដែលកំពុងបន្តដំណើរការ ដែលស៊ើបអង្កេតទៅលើការរៀបចំផែនការ ការញុះញង់ ការបញ្ជា ការជួយ និងជំរុញ ឬការប្រព្រឹត្តិជាលក្ខណៈបុគ្គល ឬតាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ចំពោះបទឧក្រិដ្ឋដូចតទៅ៖ ការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ[5]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានជូនដំណឹងដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ ថា "ការចោទប្រកាន់ទាំងនេះគឺផ្អែកលើមូលដ្ឋានទាំងអង្គហេតុដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងអង្គហេតុដែលត្រូវបានរកឃើញនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ"[6]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានជូនដំណឹងទៅម្ចាស់បណ្តឹងឧទ្ធរណ៍ថា អនុលោមតាមវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង គាត់ ក្នុងនាមជាជនសង្ស័យ មានសិទ្ធិមួយចំនួន

---

[3] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី របស់សហព្រះរាជអាជ្ញា, ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨, ឯកសារ D1។ ការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ស្តីពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី, ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩,ឯកសារ D1/1។

[4] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់របស់សហព្រះរាជអាជ្ញា ទាក់ទងទីតាំងឧក្រិដ្ឋកម្មតំបន់ ១ និងការធ្វើទុក្ខបុកម្នេញលើខ្មែរក្រោម, ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារ D65 និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាលើយេនឌ័រ, ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤, ឯកសារ D191។

[5] ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន២១(១)(ឃ)], ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D109។

[6] ដូចជើងទំព័រខាងលើ កថាខណ្ឌ២។

រួមទាំងសិទ្ធិចូលពិនិត្យមើលសំណុំរឿង "អនុវត្តស្រដៀងគ្នា តាមវិធាន ៥៥(៦), វិធាន ៥៥(១) និងវិធាន ៥៨[...][7]"។ ការជូនដំណឹងរបស់ ស.ច.ស.អ.ប ត្រូវបានប្រគល់ទៅឱ្យចៅរបស់ជនសង្ស័យ ឈ្មោះ [redacted] និងក្មួយប្រុសរបស់ជនសង្ស័យឈ្មោះ [redacted] ដោយក្រឡាបញ្ជីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") នៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២ នៅវេលាម៉ោង ៥ និង ៥០ នាទីល្ងាច និងក្រោយមកនៅម៉ោង ៤ និង ១០ នាទីល្ងាច[8]។

3. នៅថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានជូនដំណឹងដល់អង្គភាពគាំពារការការពារក្តី អំពីការជូនដំណឹងរបស់ ស.ច.ស.អ.ប និងបានបង្គាប់ថា អង្គភាពគាំពារការការពារក្តី ត្រូវផ្តល់ដល់ជនសង្ស័យនូវបញ្ជីឈ្មោះមេធាវី ព្រមទាំងជួយដល់ជនសង្ស័យ ដោយអនុលោមតាមវិធាន ១១ នៃវិធានផ្ទៃក្នុង[9]។

4. នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៣ ប្រធានអង្គភាពគាំពារការការពារក្តីបានចាត់តាំងបណ្តោះអាសន្ន លោក សូ មូស្សេនី ជាសហមេធាវីជាតិរបស់ [redacted][10]។ នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣ ប្រធានអង្គភាពគាំពារការការពារក្តីបានបញ្ជូនសំណើទៅ ក.ស.ច.ស ស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យចេញដីកាសម្រេចទទួលស្គាល់លោក សូ មូស្សេនី ជាសហមេធាវី ដែលត្រូវបានចាត់តាំងបណ្តោះអាសន្ន តាមមាត្រា ២១(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក[11]។

5. នៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៤ លោក សូ មូស្សេនី បានដាក់លិខិតមួយទៅក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ស្នើសុំចូលពិនិត្យមើលសំណុំរឿង ០០៤។ ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានឆ្លើយតបទៅលោក សូ មូស្សេនី ថា "ការិយាល័យសហ

---

[7] ដូចដើងទំព័រខាងលើ កថាខណ្ឌ៤។

[8] និវេទន៍នៃការមិនទទួលការជូនដំណឹង, ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D109.1។

[9] ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធានផ្ទៃក្នុង ២១(១)(ឃ)], ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D111 កថាខណ្ឌ ៣ និង៦។

[10] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "លោក ប៊ិត សៀងលីម និងលោក សូ មូស្សេនី ត្រូវបានចាត់តាំងជាមេធាវីការពារក្តីតំណាងជនសង្ស័យពីររូបក្នុងសំណុំរឿង ០០៤" ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៣ មាននៅ http://www.eccc.gov.kh/en/articles/mr-bit-seanglim-and-mrso-mosseny-assigned-defence-counsel-represent-two-suspects-case-004។

[11] សារអេឡិចត្រូនិកពី Isaac ENDELEY ផ្ញើទៅលោក សូ មូស្សេនី និង Neville SORAB "លិខិតជូនការិយាល័យសហចៅក្រមស៊ើបអង្កេត", ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ D186.1.2។

ចៅក្រមស៊ើបអង្កេតមិនទាន់បានទទួលឯកសារណាមួយពីអង្គភាពគាំពារការការពារក្ដី ទាក់ទងការតែងតាំង [លោក សូ មូស្សេទ្ធិ] ជាសហមេធាវីជាតិរបស់ជនសង្ស័យដែលមានឈ្មោះក្នុងសំណុំរឿង ០០៤ នៅឡើយ។ [ក្រឡាបញ្ជី] បាននិយាយថា គាត់បានឮពីការតែងតាំងនេះនៅក្នុងព័ត៌មានកាលពីថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៣ ប៉ុន្តែ តាមការអនុវត្តទូទៅ អង្គភាពគាំពារការការពារក្ដីត្រូវបញ្ជូនឯកសារតែងតាំងទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយការិយាល័យសហចៅក្រមស៊ើបអង្កេតនឹងសម្រេចលើការទទួលស្គាល់ និងការចូលទៅក្នុង Zylab"[12]។

6. នៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ អង្គភាពគាំពារការការពារក្ដីបានផ្ដល់កិច្ចសន្យាការងារបណ្ដោះអាសន្នទៅលោកស្រី Suzana TOMANOVIĆ ក្នុងគោលបំណងឱ្យគាត់ធ្វើជាអ្នកតំណាងតាមផ្លូវច្បាប់របស់ [redacted] ក្នុងនាមជាសហមេធាវីអន្តរជាតិរបស់គាត់[13]។

7. នៅថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៤ លោក សូ មូស្សេទ្ធិ បានបន្តសាកសួរទៅក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត អំពីសំណើចូលពិនិត្យមើលសំណុំរឿង[14]។ ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត បានទទួលស្គាល់ការទទួលបានសំណើទាំងនេះ ហើយបានជូនដំណឹងទៅលោក សូ មូស្សេទ្ធិថា គាត់កំពុងរង់ចាំចម្លើយតបពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[15]។

8. នៅថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៤ លោក សូ មូស្សេទ្ធិ និងលោកស្រី TOMANOVIĆ បានដាក់សំណើបន្ទាន់មួយនៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយស្នើសុំចូលពិនិត្យមើលសំណុំរឿង ០០៤ និងចូលរួមក្នុងកិច្ចស៊ើបសួរ ("សំណើបន្ទាន់")[16]។ នៅក្នុងសំណើបន្ទាន់

---

[12] សារអេឡិចត្រូនិកពី សូ មូស្សេទ្ធិ "Re: ឯកសារតែងតាំង" ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៤, ឯកសារ D186.1.3។

[13] សំណើសុំបន្ទាន់របស់ [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ, ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ D186/2, កថាខណ្ឌ ៤។

[14] សារអេឡិចត្រូនិករបស់ សូ មូស្សេទ្ធិ ផ្ញើទៅ លី ចាន់តុលា "សំណើបន្ទាប់ សុំចូលពិនិត្យមើលក្នុង Zylab", ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ D186.1.6។

[15] សារអេឡិចត្រូនិករបស់ លី ចាន់តុលា ផ្ញើទៅ សូ មូស្សេទ្ធិ "Re: សំណើបន្ទាប់ សុំចូលពិនិត្យមើលក្នុង Zylab", ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ D186.1.6។

[16] សំណើជាបន្ទាន់របស់ [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ, ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ D186។

នោះ លោក សូ មូស្សេឡឺ និងលោកស្រី TOMANOVIĆ បានកត់សម្គាល់ទៅលើចំណុចដែលថា ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនទាន់ចេញដីកាសម្រេចទទួលស្គាល់ការតែងតាំងជាផ្លូវការនោះទេ[17] ហើយបានស្នើសុំឱ្យ ក.ស.ច.ស "ចេញដីកាបង្គាប់ឱ្យការិយាល័យរដ្ឋបាលផ្តល់សិទ្ធិចូលពិនិត្យមើលសំណុំរឿង ដល់ក្រុមមេធាវីការពារក្តី"[18]។ ពួកគេបានលើកទឡ្ហីករណ៍ថា ការមិនមានចម្លើយតបរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត អាចត្រូវបានចាត់ទុកថាជាការបដិសេធតាមការសន្មតទៅលើសិទ្ធិចូលពិនិត្យមើលសំណុំរឿង ០០៤[19] ថា បុគ្គលដែលមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរដែលជា "កម្មវត្ថុនៃការចោទប្រកាន់" ត្រូវទទួលបានសិទ្ធិជាស្វ័យប្រវត្តិដូចគ្នានឹង "ជនត្រូវចោទ"[20] ហើយថា ម្ចាស់បណ្តឹងឧទ្ធរណ៍ ត្រូវតែទទួលបានសិទ្ធិក្នុងការរៀបចំការការពារខ្លួន អនុលោមតាមវិធាន ២១[21] នៃវិធានផ្ទៃក្នុង បើមិនដូច្នោះទេសិទ្ធិរបស់គាត់ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ និងការប្រព្រឹត្តិស្មើភាពគ្នា នឹងត្រូវបានរំលោភមិនខាន[22]។

9. នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលស្គាល់ការតែងតាំងលោក សូ មូស្សេឡឺ និងលោកស្រី TOMANOVIĆ ជាសហមេធាវីការពារក្តីរបស់ [redacted][23]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកត់សម្គាល់ថា ការតែងតាំងនេះជាការតែងតាំងបណ្តោះអាសន្ន ដោយរង់ចាំការសម្រេចរបស់អង្គភាពគាំពារការការពារក្តី ទៅលើភាពក្រីក្ររបស់ [redacted]។

10. នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីជូនដំណឹងទាក់ទងនឹងសំណើជាបន្ទាន់របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ("សេចក្តីជូនដំណឹងស្តីពីការពន្យារ

[17] ដូចដើងទំព័រខាងលើ កថាខណ្ឌ ១៦។

[18] ដូចដើងទំព័រខាងលើ កថាខណ្ឌចុងក្រោយ។

[19] ដូចដើងទំព័រខាងលើ កថាខណ្ឌ១៧។

[20] ដូចដើងទំព័រខាងលើ កថាខណ្ឌ ១៨ ដល់ ២៧។

[21] ដូចដើងទំព័រខាងលើ កថាខណ្ឌ ២៨ និងកថាខណ្ឌ ៣៤ ដល់ ៣៦។

[22] ដូចដើងទំព័រខាងលើ កថាខណ្ឌ ២៩ ដល់ ៣៣។

[23] ដីកាសម្រេចទទួលស្គាល់សហមេធាវីការពារក្តីជនសង្ស័យ [redacted] ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D122/9/6។

ពេល")[24]។ នៅក្នុងសេចក្តីជូនដំណឹងស្តីពីការពន្យារពេល បានជូនដំណឹងថា សេចក្តីជូនដំណឹងរបស់ ស.ច.ស.អ.ប នេះ ផ្តល់ឱ្យជនសង្ស័យនូវសិទ្ធិមួយចំនួន ក្នុងចំណោមសិទ្ធិទាំងនោះ មានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ០០៤ នោះ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានជូនដំណឹងដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ អំពីគោលបំណងក្នុងការពិចារណាឡើងវិញលើការជូនដំណឹងរបស់ ស.ច.ស.អ.ប តែនៅត្រង់ចំណុចនេះ[25] ហើយដោយសារតែផ្នែកនេះក្នុងការជូនដំណឹងរបស់ ស.ច.ស.អ.ប ទាក់ទងនឹងសំណើបន្ទាន់នោះ ទើបសម្រេចពន្យារពេលក្នុងការចេញដីកាសម្រេចលើសំណើបន្ទាន់រហូតដល់ពេលបានទទួលសារណាពី ម្ចាស់បណ្តឹងឧទ្ធរណ៍ និងភាគីនានា ទាក់ទងនឹងការពិចារណាឡើងវិញលើការជូនដំណឹង របស់ ស.ច.ស.អ.ប[26]។

11. នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ សហមេធាវីបានដាក់ នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត នូវសំណើជាបន្ទាន់របស់ [redacted] សុំដំណោះស្រាយដោយផ្អែកលើព័ត៌មានថ្មី ("សំណើសុំដំណោះស្រាយ") ដោយបានស្នើសុំសិទ្ធិចូលពិនិត្យមើលសំណុំរឿង ០០៤ ភ្លាមៗ នៅពេលរង់ចាំការពិចារណាឡើងវិញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើការជូនដំណឹងរបស់ស.ច.ស.អ.ប[27]។ សហមេធាវីបានលើកទឡ្ហីករណ៍ថាសេចក្តីជូនដំណឹងស្តីពីការពន្យារពេល បានផ្តល់ព័ត៌មានថ្មីដែលសហមេធាវីមិនបានដឹងកាលពីមុន ដែលថាការជូនដំណឹងរបស់ ស.ច.ស.អ.ប បានផ្តល់សិទ្ធិចូលពិនិត្យមើលសំណុំរឿង ហើយការអនុញ្ញាតនេះមិនដែលត្រូវបានពិចារណាសាជាថ្មីឡើងវិញ បដិសេធ ឬទុកជាមោឃៈឡើយ[28]។ អាស្រ័យហេតុនេះ សហមេធាវីបញ្ជាក់ថា សិទ្ធិចូលពិនិត្យមើលសំណុំរឿងដែលត្រូវបានផ្តល់ឱ្យ*តាមផ្លូវច្បាប់* (*de jure*) ត្រូវបានបដិសេធ "តាមអំពើចិត្ត" *តាមភាពជាក់ស្តែង* (*de facto*)[29]។

---

[24] សេចក្តីជូនដំណឹងទាក់ទងនឹងសំណើជាបន្ទាន់របស់ [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤, ឯកសារ D186/1។

[25] ដូចដើងទំព័រខាងលើ កថាខណ្ឌ១ និង៧។

[26] ដូចដើងទំព័រខាងលើ ទំព័រ ៥។

[27] សំណើជាបន្ទាន់របស់ [redacted] សុំដំណោះស្រាយដោយផ្អែកលើព័ត៌មានថ្មី, ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤, ឯកសារ D192។

[28] ដូចដើងទំព័រខាងលើ កថាខណ្ឌ ៧។

[29] ដូចដើងទំព័រខាងលើ ទំព័រ១។

12. នៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចបដិសេធលើសំណើសុំដំណោះស្រាយ ដោយមិនធ្វើឲ្យប៉ះពាល់ដល់សំណើបន្ទាន់ ("ដីកាសម្រេចដែលរងការជំទាស់ទីមួយ")[30]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរំលឹកថា ទោះបីជាគាត់បានពិចារណាឡើងវិញរួចហើយ ព្រមទាំងបានមោឃភាពលើការជូនដំណឹងរបស់ ស.ច.ស.អ.ប ព្រមទាំងបានបដិសេធលើសិទ្ធិចូលពិនិត្យមើលសំណុំរឿង ចំពោះជនសង្ស័យផ្សេងនៅក្នុងសំណុំរឿង ០០៤ ("សេចក្តីសម្រេចស្តីពី [redacted]") ហើយក៏ដោយ[31] ប៉ុន្តែគាត់មិនទាន់បានទទួលសារណាបន្ថែមទៀតពីម្ចាស់បណ្តឹងឧទ្ធរណ៍ និងភាគីនានា ចំពោះបញ្ហានៃការពិចារណាឡើងវិញលើការជូនដំណឹងរបស់ ស.ច.ស.អ.ប ចំពោះម្ចាស់បណ្តឹងឧទ្ធរណ៍នៅឡើយទេ[32]។ ទោះជាយ៉ាងនេះក្តី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ*បានសម្រេចរួចហើយនៅក្នុងដីកាសម្រេចដែលរងការជំទាស់ទីមួយ* ថា ការជូនដំណឹងរបស់ ស.ច.ស.អ.ប អាចត្រូវបានចាត់ទុកថាជាការរំលោភបំពានទៅលើឆន្ទានុសិទ្ធិតុលាការ ព្រោះម្ចាស់បណ្តឹងឧទ្ធរណ៍ ត្រូវបានផ្តល់ឲ្យនូវសិទ្ធិ ដែលវិធានផ្ទៃក្នុងមិនបានផ្តល់ឲ្យ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងមិនបានផ្តល់សំអាងហេតុណាមួយ ដើម្បីគាំទ្រដល់ការជូនដំណឹងរបស់ ស.ច.ស.អ.ប ឡើយ[33]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់ថា ម្ចាស់បណ្តឹងឧទ្ធរណ៍ មិនមែនជាជនត្រូវចោទទេ ដូចនេះ បញ្ញត្តិជាធរមានមិនបានផ្តល់សិទ្ធិឲ្យគាត់ចូលពិនិត្យមើលសំណុំរឿងឡើយ[34]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបន្តអះអាងថា ដោយសារតែវិធាន ៥៦ នៃវិធានផ្ទៃក្នុង ចែងថា កិច្ចស៊ើបសួរត្រូវរក្សាការសម្ងាត់ ការផ្តល់សិទ្ធិដល់ជនសង្ស័យឲ្យចូលពិនិត្យមើលសំណុំរឿង មិនមែនជាប្រយោជន៍យុត្តិធម៌ទេ ហើយអាចធ្វើឲ្យប៉ះពាល់ដល់ការសម្ងាត់នៃកិច្ចស៊ើបសួរផង[35]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

---

[30] ដីកាសម្រេចលើសំណើជាបន្ទាន់របស់ [redacted] សុំដំណោះស្រាយដោយផ្អែកលើព័ត៌មានថ្មី, ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤, ឯកសារ D192/1, ("ដីកាសម្រេចដែលរងការជំទាស់ទីមួយ")។

[31] ដូចដើងទំព័រខាងលើ កថាខណ្ឌ៧ យោងទៅសេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តី [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត, ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣, ឯកសារ D121/4 ("សេចក្តីសម្រេចស្តីពី [redacted]") កថាខណ្ឌ ៣៦ ដល់៤៩ និង៦១។

[32] ដូចដើងទំព័រខាងលើ កថាខណ្ឌ១២។

[33] ដីកាសម្រេចដែលរងការជំទាស់ទីមួយ។

[34] ដូចដើងទំព័រខាងលើ កថាខណ្ឌ៨។

[35] ដូចដើងទំព័រខាងលើ កថាខណ្ឌ៩។

បានពិចារណាឃើញបន្ថែមទៀតនៅក្នុងដីកាសម្រេចដែលរងការជំទាស់ទីមួយថា ការមិនអាចចូលពិនិត្យមើលសំណុំរឿងរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ មិនបានបង្កជាព្យសនកម្មដល់ជនសង្ស័យឡើយ ដោយសារតែគាត់ "មិនទាន់ជាប់ឃុំឃាំង គ្មានសំណុំរឿងដែលត្រូវឆ្លើយ ហើយក៏មិនមានការរៀបចំការការពារក្ដីដែលត្រូវធ្វើឡើងដែរ"[36]។

13. នៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៤ សហមេធាវីបានបន្តដាក់សារណារបស់ខ្លួននៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីឆ្លើយតបទៅនឹងការជូនដំណឹងស្ដីពីការពន្យារពេល ("សារណារបស់សហមេធាវីស្ដីពីការពិចារណាសាជាថ្មី")[37] ដោយស្នើសុំ ក) សិទ្ធិចូលពិនិត្យមើលសំណុំរឿងភ្លាមៗ ខ) មិនឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាសាជាថ្មីទៅលើការជូនដំណឹងរបស់ ស.ច.ស.អ.ប និង គ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់សំណើសុំមោឃភាពកិច្ចស៊ើបសួរចាប់ពីថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៤ ទៅអង្គបុរេជំនុំជម្រះ នៅពេលដែលមានសំណើសុំចូលពិនិត្យមើលសំណុំរឿង រហូតដល់ពេលដែលសំណើសុំសិទ្ធិចូលមើលត្រូវបានអនុញ្ញាតឱ្យ[38]។ នៅក្នុងសារណារបស់សហមេធាវីស្ដីពីការពិចារណាសាជាថ្មី សហមេធាវីបានធ្វើការសង្កេតចំនួនបី។ ទីមួយ សហមេធាវីបានលើកទឡ្ហីករណ៍ថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ត្រូវទទួលបានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ព្រោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានមូលដ្ឋានផ្លូវច្បាប់ដើម្បីពិចារណាសាជាថ្មីលើការជូនដំណឹងរបស់ ស.ច.ស.អ.ប ទេ[39] ហើយដោយសារតែការសម្រេចនេះធ្វើឡើង*ដោយឯកឯង* (*proprio motu*) ដោយពុំមានការផ្លាស់ប្ដូរកាលៈទេសៈ ហើយវាមិនបានដោះស្រាយទេ តែជាមូលហេតុនៃភាពអយុត្តិធម៌[40]។ ទីពីរ សហមេធាវីបានលើកឡើងថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ ដែលជាកម្មវត្ថុនៃការចោទប្រកាន់ ត្រូវទទួលបានជាស្វ័យប្រវត្តិនូវសិទ្ធិដូចគ្នានឹងជនត្រូវចោទ ហើយដោយសារតែការស៊ើបអង្កេតបានបន្តអស់រយៈពេលបួនឆ្នាំកន្លះ ការពន្យារពេលបន្ថែមទៀតក្នុងការផ្ដល់សិទ្ធិចូលពិនិត្យមើលសំណុំរឿង នឹងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទទួលបាន

---

[36] ដូចជើងទំព័រខាងលើ កថាខណ្ឌ១០។

[37] សារណារបស់ [redacted] ស្ដីពីការពិចារណាសាជាថ្មី ទៅលើសេចក្ដីសម្រេចក្នុងការអនុញ្ញាតឱ្យ [redacted] ចូលពិនិត្យមើលសំណុំរឿង, ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ D186/2។

[38] ដូចជើងទំព័រខាងលើ កថាខណ្ឌសេចក្ដីសន្និដ្ឋាន។

[39] ដូចជើងទំព័រខាងលើ កថាខណ្ឌ៩ ដល់១០។

[40] ដូចជើងទំព័រខាងលើ កថាខណ្ឌ១១ ដល់១៧។

ការជំនុំជម្រះប្រកបដោយយុត្តិធម៌ ការទទួលបានសច្ចភាពផ្លូវច្បាប់ តម្លាភាពនៃកិច្ចដំណើរការនីតិវិធី សមភាពរបស់គូភាគី និងពេលវេលា ព្រមទាំងមធ្យោបាយគ្រប់គ្រាន់ ក្នុងការរៀបចំការការពារខ្លួនរបស់គាត់[41]។ ជាចុងក្រោយ សហមេធាវីបានលើកទឡ្ហីករណ៍ថា ការបដិសេធ *ដាក់ស្តែង* ទៅលើការផ្តល់សិទ្ធិ *តាមផ្លូវច្បាប់* ឲ្យចូលពិនិត្យមើលសំណុំរឿង គឺជាកំហុសផ្នែកនីតិវិធី ហើយដោយយោងទៅលើបញ្ញត្តិនៃវិធាន ៤៨ និងវិធាន ៧៦(២) នៃវិធានផ្ទៃក្នុង បានស្នើសុំធ្វើមោឃភាពការស៊ើបអង្កេតចាប់ពីថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៤ គឺនៅពេលដែលមានការស្នើសុំចូលពិនិត្យមើលសំណុំរឿង រហូតដល់ពេលដែលម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានផ្តល់ឲ្យនូវសិទ្ធិចូលពិនិត្យមើលសំណុំរឿង[42]។ មិនមានភាគីណាមួយនៃកិច្ចដំណើរការនីតិវិធីស៊ើបអង្កេត បានដាក់សារណា ណាមួយផ្សេងទៀតនៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងបញ្ហានៃការពិចារណាសាជាថ្មីទៅលើការជូនដំណឹងរបស់ ស.ច.ស.អ.ប ឡើយ។

14. នៅថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ សហមេធាវីបានដាក់បណ្តឹងឧទ្ធរណ៍ទីមួយប្រឆាំងដីកាសម្រេចដែលរងការជំទាស់ទីមួយទៅអង្គបុរេជំនុំជម្រះ ដោយស្នើដល់អង្គបុរេជំនុំជម្រះឲ្យច្រានចោលដីកាសម្រេចដែលរងការជំទាស់ទីមួយ ហើយបង្គាប់ដល់ការិយាល័យសហចៅក្រមស៊ើបអង្កេតឲ្យផ្តល់ដល់មេធាវីការពារក្តីនូវសិទ្ធិចូលពិនិត្យមើលសំណុំរឿង *ភ្លាមៗ ក្នុងពេលរង់ចាំការពិចារណាសាជាថ្មីណាមួយ*របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើការជូនដំណឹងរបស់ ស.ច.ស.អ.ប[43]។

15. នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេចមួយលុបចោល "ការអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង" ហើយបដិសេធលើសំណើបន្ទាន់ និងសំណើដែលបានស្នើនៅក្នុងសារណារបស់សហមេធាវីស្តីពីការពិចារណាសាជាថ្មី ("ដីកាសម្រេចដែលរងការជំទាស់ទីពីរ")[44]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្តល់សំអាងហេតុសម្រាប់

[41] ដូចជើងទំព័រខាងលើ កថាខណ្ឌ១៨ ដល់៤២។

[42] ដូចជើងទំព័រខាងលើ កថាខណ្ឌ៤៣ ដល់៤៨។

[43] បណ្តឹងឧទ្ធរណ៍ទីមួយ, កថាខណ្ឌ សេចក្តីសន្និដ្ឋាន។

[44] ដីកាសម្រេចលើសំណើជាបន្ទាន់របស់ [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ, ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤, ឯកសារD186/3 ("ដីកាសម្រេចដែលរងការជំទាស់ទីពីរ")។

ដីកាសម្រេចដែលរងការជំទាស់ទីពីរ ដូចតទៅ៖ ទីមួយ[45] ដោយផ្អែកទៅលើអំណាចឆន្ទានុសិទ្ធិដែលមានស្រាប់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិធ្វើការពិចារណាឡើងវិញ ហើយលុបចោលផ្នែកនៃការជូនដំណឹងរបស់ ស.ច.ស.អ.ប ដែលអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង ព្រោះដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់ ការជូនដំណឹងនេះធ្វើឡើងដោយគ្មានសំអាងហេតុ ហើយមិនមានការគាំទ្រពីបញ្ញត្តិនៃវិធានផ្ទៃក្នុង ដែលមិនបានផ្តល់សិទ្ធិបែបនេះដល់ជនសង្ស័យដែលអាច ឬអាចមិនត្រូវបានចោទប្រកាន់។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបន្ថែមថា ការផ្តល់សិទ្ធិបែបនេះទៅឱ្យអ្នកមិនមែនជាភាគីនៃកិច្ចដំណើរការនីតិវិធី មិនមែនជាប្រយោជន៍យុត្តិធម៌ទេ ហើយអាចធ្វើឱ្យប៉ះពាល់ដល់ការសម្ងាត់នៃកិច្ចស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានកត់សម្គាល់ផងដែរអំពីចំណុចដែលថា ការជូនដំណឹងរបស់ ស.ច.ស.អ.ប មិនបានផ្តល់ដល់ជនសង្ស័យនូវសិទ្ធិណាមួយក្នុងការចូលរួមក្នុងកិច្ចស៊ើបសួរឡើយ។ ទីពីរ[46] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអះអាងម្តងទៀតពីមតិយោបល់របស់គាត់ ដែលបានលើកឡើងកាលពីពេលមុន នៅក្នុងដីកាសម្រេចបដិសេធសំណើសុំចូលពិនិត្យមើលសំណុំរឿងរបស់ជនសង្ស័យផ្សេងទៀត[47] ដែលថា ជនសង្ស័យមិនមែនជាជនត្រូវចោទដូចមានចែងក្នុងវិធានផ្ទៃក្នុង ហើយគាត់ក៏មិនបានទទួលរងការ "ប៉ះពាល់យ៉ាងធ្ងន់ធ្ងរ" ដោយសារកិច្ចស៊ើបអង្កេតឡើយ ហើយថា វិធានផ្ទៃក្នុងដែលបែងចែកដាច់ពីគ្នាអំពីសិទ្ធិរបស់ជនសង្ស័យ និងសិទ្ធិរបស់ជនត្រូវចោទនោះ មិនបានផ្តល់ដល់ជនសង្ស័យនូវសិទ្ធិចូលពិនិត្យមើលសំណុំរឿងឡើយ។ ទីបី[48] សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា ទឡ្ហីករណ៍របស់សហមេធាវីដែលថា ការចូលពិនិត្យមើលសំណុំរឿងគឺចាំបាច់សម្រាប់ការចូលរួមប្រកបដោយអត្ថន័យនៅក្នុងកិច្ចស៊ើបសួរនោះ មិនបានធ្វើការពិចារណាទៅលើវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ដែលផ្តល់សិទ្ធិចូលរួមតែចំពោះជនត្រូវចោទប៉ុណ្ណោះ មិនចំពោះជនសង្ស័យឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានបញ្ជាក់ផងដែរថា គាត់ត្រូវធានាថាភាគីទាំងអស់មានពេលវេលាគ្រប់គ្រាន់ក្នុងការប្រើប្រាស់ដោយប្រសិទ្ធភាពនូវសិទ្ធិបែបនេះ មុន

[45] ដីកាសម្រេចដែលរងការជំទាស់ទីពីរ កថាខណ្ឌ ២០ ដល់២៥។

[46] ដីកាសម្រេចដែលរងការជំទាស់ទីពីរ, កថាខណ្ឌ ២៦ ដល់២៨។

[47] សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត, ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣, ឯកសារ D121/4។

[48] ដីកាសម្រេចដែលរងការជំទាស់ទីពីរ, កថាខណ្ឌ ២៩។

ពេលបិទបញ្ចប់កិច្ចស៊ើបអង្កេត។ ទីបួន[49] សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា ពេលវេលាខុសគ្នាក្នុងការចោទប្រកាន់ក្នុងសំណុំរឿង ០០២ និង ០០៤ មិនអាចចាត់ទុកថាជាការរំលោភទៅលើសិទ្ធិរបស់ជនសង្ស័យ ក្នុងការទទួលបានការប្រព្រឹត្តិដូចគ្នា ហេតុដូច្នេះការកំណត់ពេលវេលាគឺអាស្រ័យលើការវាយតម្លៃលើភស្តុតាងដែលប្រមូលបានក្នុងសំណុំរឿងនីមួយៗ។ បន្ថែមពីលើនេះដោយយោងទៅលើយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនានា សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា សិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ មិនតម្រូវថា ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ ត្រូវទទួលបានពេលវេលាក្នុងកម្រិតដូចគ្នានឹងសហព្រះរាជអាជ្ញា ឬភាគីដទៃឡើយ។ ទីប្រាំ[50] ដោយយោងទៅលើការសម្រេចប្រហាក់ប្រហែលគ្នាកន្លងមក សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា ជនសង្ស័យនេះ ដែលមិនមែនជាភាគីនៃកិច្ចដំណើរការនីតិវិធី ក៏មិនមានសិទ្ធិក្នុងការដាក់សំណើសុំមោឃភាព ដោយអនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុងដែរ។

16. នៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៤ សហមេធាវីបានដាក់ការជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចដែលរងការជំទាស់ទីពីរ ហើយនៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ ពួកគេបានដាក់បណ្តឹងឧទ្ធរណ៍ទីពីរ។ បណ្តឹងឧទ្ធរណ៍ទីពីរត្រូវបានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ និងជាភាសាខ្មែរនៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤។

17. ម្ចាស់បណ្តឹងឧទ្ធរណ៍ពុំបានស្នើសុំឱ្យមានសវនាការលើបណ្តឹងឧទ្ធរណ៍ ហើយក៏ពុំមានការដាក់ចម្លើយតបណាមួយទៅនឹងបណ្តឹងឧទ្ធរណ៍ នៅក្នុងអំឡុងកាលបរិច្ឆេទតាមផ្លូវច្បាប់ឡើយ។

## II. **សារណាលើបណ្តឹងឧទ្ធរណ៍**

### **បណ្តឹងឧទ្ធរណ៍ទីមួយ**

18. នៅក្នុងបណ្តឹងឧទ្ធរណ៍ទីមួយ សហមេធាវីបានស្នើដល់អង្គបុរេជំនុំជម្រះឱ្យផ្តល់នូវដំណោះស្រាយដូចតទៅ៖ ១) សុំឱ្យអង្គបុរេជំនុំជម្រះសម្រេចថា បណ្តឹងឧទ្ធរណ៍ទីមួយអាចទទួលយកបាន ២) បដិសេធដីកាសម្រេចដែលរងការជំទាស់ទីមួយ[51] និង ៣) បង្គាប់ដល់ការិយាល័យសហចៅក្រម

---

[49] ដីកាសម្រេចដែលរងការជំទាស់ទីពីរ, កថាខណ្ឌ ៣០ ដល់៣១។

[50] ដីកាសម្រេចដែលរងការជំទាស់ទីពីរ, កថាខណ្ឌ ៣២។

[51] បណ្តឹងឧទ្ធរណ៍ទីមួយ, កថាខណ្ឌ សេចក្តីផ្តើម។

ស៊ើបអង្កេតឲ្យផ្តល់ដល់មេធាវីការពារក្តីនូវសិទ្ធិចូលពិនិត្យមើលសំណុំរឿង*ភ្លាមៗ ក្នុងពេលរង់ចាំការពិចារណាសាជាថ្មីណាមួយ* របស់ ស.ច.ស.អ ទៅលើការជូនដំណឹងរបស់ ស.ច.ស.អ.ប[52]។

19. សហមេធាវីបានលើកឡើងថា បញ្ញត្តិនៃវិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង ដែលកំណត់ថា កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ត្រូវតែមានយុត្តិធម៌ គោរពគោលការណ៍ដេញដោលនៅចំពោះមុខ ហើយត្រូវរក្សានូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយនោះ ក៏ត្រូវអនុវត្តផងដែរចំពោះជនសង្ស័យ ហើយបានលើកទឡ្ហីករណ៍ថា បណ្តឹងឧទ្ធរណ៍ទីមួយអាចទទួលយកបានអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលតម្រូវឲ្យមានការបកស្រាយក្នុងន័យទូលាយ[53] អំពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ដើម្បីធានាថា សិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានការពារ។ សហមេធាវីបានបន្ថែមថា ប្រសិនបើបណ្តឹងឧទ្ធរណ៍ទីមួយមិនត្រូវបានយល់ព្រមតាម សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ គឺសមភាពនៃគូភាគី និងការទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំការការពារខ្លួនរបស់គាត់ "នឹងត្រូវរងការប៉ះពាល់ធ្ងន់ធ្ងរ"[54]។

20. បន្ទាប់មក សហមេធាវីបានលើកទឡ្ហីករណ៍ថា ដោយសារសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាឡើងវិញ លុបចោល ឬមោឃភាពការជូនដំណឹងរបស់ ស.ច.ស.អ.ប ទើបការជូនដំណឹងនេះនៅមានអានុភាព ហើយម្ចាស់បណ្តឹងឧទ្ធរណ៍មានសិទ្ធិ*តាមផ្លូវច្បាប់* (*de jure*) ក្នុងការចូលពិនិត្យមើលសំណុំរឿង[55]។ ហេតុដូច្នេះ សហមេធាវីបានលើកទឡ្ហីករណ៍បន្ថែមថា ម្ចាស់បណ្តឹងឧទ្ធរណ៍មានសិទ្ធិ*ជាក់ស្តែង* (*de facto*) ក្នុងការចូលពិនិត្យមើលសំណុំរឿង ហើយការបដិសេធទៅលើសិទ្ធិនេះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺ "មិនត្រូវបានផ្អែកលើច្បាប់ ឬបទប្បញ្ញត្តិណាមួយឡើយ។ ការបដិសេធនេះផ្ទុយនឹងច្បាប់ ហើយជាការបំពានលើគោលការណ៍ស្តីពីយុត្តិធម៌ និងភាពត្រឹមត្រូវនៃនីតិវិធី" ហើយបានបំពានលើ "សិទ្ធិជាមូលដ្ឋានរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការទទួលបានសច្ចភាពគតិយុត្តិ"[56]។

---

[52] ដូចជើងទំព័រខាងលើ។

[53] បណ្តឹងឧទ្ធរណ៍ទីមួយ, កថាខណ្ឌ ៦ យោងទៅជើងទំព័រ ១៥ ដែលទាក់ទងនឹងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ។

[54] បណ្តឹងឧទ្ធរណ៍ទីមួយ, កថាខណ្ឌ ៦ ដល់ ៧។

[55] បណ្តឹងឧទ្ធរណ៍ទីមួយ, កថាខណ្ឌ ៨។

[56] បណ្តឹងឧទ្ធរណ៍ទីមួយ, កថាខណ្ឌ ៩ ដល់ ១០។

21. ទីបី សហមេធាវីបានលើកឡើងថា ការមិនអាចចូលពិនិត្យមើលសំណុំរឿង បានបង្កព្យសនកម្មលើម្ចាស់បណ្ដឹងឧទ្ធរណ៍ បីយ៉ាង[57]។ ទីមួយ សហមេធាវីបានលើកឡើងថា ពួកគេមិនអាចការពារផលប្រយោជន៍របស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ នៅក្នុងកិច្ចស៊ើបអង្កេត ព្រោះពួកគេមិនទាន់ត្រូវបានអនុញ្ញាតឱ្យចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចស៊ើបអង្កេត ដែលពួកគេបានលើកឡើងថា ពួកគេត្រូវមានឱកាសចូលរួមតាំងពីដើមដំបូងបំផុត ដើម្បីធានាថា សិទ្ធិរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍មានអានុភាពពេញលេញ[58]។ ទីពីរ សហមេធាវីបានលើកឡើងថា ចាប់តាំងពីពេលដែលម្ចាស់បណ្ដឹងឧទ្ធរណ៍ ត្រូវបានជូនដំណឹងថាគាត់គឺជាជនសង្ស័យ គាត់ត្រូវទទួលបានជាស្វ័យប្រវត្តិនូវពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំការការពារខ្លួនគាត់ អនុលោមតាមមាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយការបដិសេធ *ជាក់ស្ដែង* លើការចូលពិនិត្យមើលសំណុំរឿង បានបំពានទៅលើសិទ្ធិមួយនេះ[59]។ ទីបី សហមេធាវីបានបញ្ជាក់ថា គោលការណ៍សមភាពនៃគូភាគី ដែលមានចែងនៅក្នុងមាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយដែលត្រូវបានអនុម័តយកនៅក្នុងវិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង តម្រូវថា បុគ្គលដែលត្រូវទទួលរងការចោទប្រកាន់ ត្រូវទទួលបានឱកាសដ៏សមរម្យក្នុងការបង្ហាញសំណុំរឿងរបស់ខ្លួន ក្រោមលក្ខខណ្ឌដែលមិនធ្វើឱ្យពួកគេ "ចាញ់ប្រៀបខ្លាំង" ធៀបជាមួយនឹងភាគីផ្សេងទៀត។ ដោយកត់សម្គាល់ថា សហព្រះរាជអាជ្ញាអាចចូលពិនិត្យមើលសំណុំរឿង តាំងពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ ហើយដើមបណ្ដឹងរដ្ឋប្បវេណី អាចចូលពិនិត្យ តាំងពីថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១ មកនោះ សហមេធាវីបានលើកឡើងថា ភាពខុសគ្នាក្នុងការកំណត់ពេលវេលាផ្ដល់សិទ្ធិចូលពិនិត្យមើលសំណុំរឿង និងក្នុងការអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចស៊ើបអង្កេត បានបង្កើតជាអតុល្យភាព"រវាងលទ្ធភាពរបស់ភាគីនានាក្នុងការបញ្ជាក់អះអាងពីរឿងក្ដីរបស់ខ្លួន"[60]។

22. ជាចុងក្រោយ សហមេធាវីបានលើកឡើងថា ការផ្ដល់លទ្ធភាព*ជាក់ស្ដែង* ក្នុងការចូលពិនិត្យមើលសំណុំរឿងឱ្យម្ចាស់បណ្ដឹងឧទ្ធរណ៍ គឺដើម្បីជាប្រយោជន៍យុត្តិធម៌ និងមិនធ្វើឱ្យប៉ះពាល់ដល់ការ

[57] បណ្ដឹងឧទ្ធរណ៍ទីមួយ, កថាខណ្ឌ ១១ ដល់ ២២។

[58] បណ្ដឹងឧទ្ធរណ៍ទីមួយ, កថាខណ្ឌ ១៣ ដល់ ១៦។

[59] បណ្ដឹងឧទ្ធរណ៍ទីមួយ, កថាខណ្ឌ ១៧ ដល់ ១៩។

[60] បណ្ដឹងឧទ្ធរណ៍ទីមួយ, កថាខណ្ឌ ២០ ដល់ ២២។

សម្ងាត់នៃកិច្ចស៊ើបសួរឡើយ[61]។ សហមេធាវីបានលើកឡើងថា ការផ្តល់សិទ្ធិ *ជាក់ស្តែង* ដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ គឺជាប្រយោជន៍យុត្តិធម៌ ព្រោះជាការបញ្ឈប់ការរំលោភបំពានដែលកំពុងមានចំពោះសិទ្ធិរបស់គាត់[62]។ បន្ថែមពីលើនេះ សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានផ្តល់សំអាងហេតុ ឬបញ្ជាក់ច្បាស់លាស់ថាតើការចូលពិនិត្យមើលសំណុំរឿងរបស់ [redacted] ធ្វើឲ្យប៉ះពាល់ដោយរបៀបណាចំពោះការរក្សាការសម្ងាត់ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏មិនបានផ្តល់ភស្តុតាងដែលបង្ហាញថា ការចូលពិនិត្យមើលសំណុំរឿងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ធ្វើឲ្យប៉ះពាល់ចំពោះការរក្សាការសម្ងាត់ដែរ។ សហមេធាវីបានលើកឡើងថា ហេតុដូច្នេះ ការអះអាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះបញ្ហានេះ គឺជាការរំលោភបំពានទៅលើឆន្ទានុសិទ្ធិតុលាការរបស់គាត់[63]។

**បណ្តឹងឧទ្ធរណ៍ទីពីរ**

23. នៅក្នុងបណ្តឹងឧទ្ធរណ៍ទីពីរ មេធាវីការពារក្តីបានស្នើដល់អង្គបុរេជំនុំជម្រះឲ្យ "១) ទទួលយកបណ្តឹងឧទ្ធរណ៍ ២) បង្គាប់ដល់ការិយាល័យសហចៅក្រមស៊ើបអង្កេតអនុញ្ញាតឲ្យមេធាវីការពារក្តីបានចូលពិនិត្យមើលសំណុំរឿងភ្លាម និង ៣) មោឃភាពកិច្ចស៊ើបសួររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចាប់ពីថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៤ រហូតដល់កាលបរិច្ឆេទដែលមេធាវីការពារក្តីត្រូវបានអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង"[64]។

24. មេធាវីការពារក្តីបានលើកទឡ្ហីករណ៍ថា បណ្តឹងឧទ្ធរណ៍ទីពីរអាចទទួលយកបាន ដោយផ្អែកទៅលើវិធាន ២១ នៃវិធានផ្ទៃក្នុងតែមួយ ព្រោះសិទ្ធិជាសារវន្តរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ តម្លាភាពនៃកិច្ចដំណើរការនីតិវិធី សមភាពនៃគូភាគី និងការទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការការពារខ្លួនរបស់គាត់ នឹងត្រូវទទួលរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ប្រសិនបើពុំមានសិទ្ធិប្តឹងឧទ្ធរណ៍នោះ។ មេធាវីការពារក្តីបានស្នើឡើងថា ដោយសារតែវិធាន ២១ នៃវិធានផ្ទៃក្នុងអាចអនុវត្តផងដែរចំពោះជនសង្ស័យនោះ អង្គបុរេជំនុំជម្រះអាច

[61] បណ្តឹងឧទ្ធរណ៍ទីមួយ, កថាខណ្ឌ ២៣ ដល់ ២៥។

[62] បណ្តឹងឧទ្ធរណ៍ទីមួយ, កថាខណ្ឌ ២៤។

[63] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៥។

[64] បណ្តឹងឧទ្ធរណ៍ទីពីរ, ទំព័រ ២៥។

អនុម័តយកការបកស្រាយក្នុងន័យទូលាយទៅលើសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍ ដើម្បីធានាថា សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនសង្ស័យ ត្រូវបានការពារក្នុងលក្ខណៈប្រហាក់ប្រហែលគ្នាដូចដែលអង្គជំនុំជម្រះធ្លាប់បានអនុវត្តកន្លងមក ទាក់ទិនទៅនឹងសិទ្ធិរបស់ជនត្រូវចោទដែរ[65]។ មេធាវីការពារក្ដីព្យាយាមជំទាស់ទៅលើដីកាសម្រេចទីពីរ ដោយផ្អែកលើមូលដ្ឋានចំនួនបី។

25. ទីមួយ មេធាវីការពារក្ដីបានលើកទឡ្ហីករណ៍ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងក្នុងការយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់គាត់ ហើយបានប្រព្រឹត្តិកំហុសឆ្គងក្នុងការផ្ដល់សំអាងហេតុ អនុញ្ញាតឱ្យម្ចាស់បណ្ដឹងឧទ្ធរណ៍ ចូលពិនិត្យមើលសំណុំរឿង[66]។ មេធាវីការពារក្ដីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានបំពេញតាមបទដ្ឋានសម្រាប់ការពិចារណាឡើងវិញលើការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ហើយបានបង្ហាញទឡ្ហីករណ៍ថា ទោះក្នុងកាលៈទេសៈណាក៏ដោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងមិនមានកំហុសឆ្គងក្នុងការផ្ដល់សំអាងហេតុអនុញ្ញាតឱ្យម្ចាស់បណ្ដឹងឧទ្ធរណ៍ ចូលពិនិត្យមើលសំណុំរឿងឡើយ។ ដោយជំទាស់ទៅនឹងការយល់ឃើញនៅក្នុងដីកាសម្រេចទីពីរ មេធាវីការពារក្ដីបានលើកឡើងថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ដែលជា "កម្មវត្ថុនៃការចោទប្រកាន់" គួរតែត្រូវបានចាត់ទុកថាជាជនត្រូវចោទ ដូច្នេះគាត់ត្រូវទទួលបានសិទ្ធិក្នុងការចូលពិនិត្យមើលសំណុំរឿង។ ម្ចាស់បណ្ដឹងឧទ្ធរណ៍ មិនចាំបាច់ត្រូវទទួលការចោទប្រកាន់ជាផ្លូវការ ដើម្បីអាចទទួលបានសិទ្ធិចូលពិនិត្យមើលសំណុំរឿងឡើយ ព្រោះតាមការយល់ដឹងរបស់មេធាវីការពារក្ដី សហចៅក្រមស៊ើបអង្កេតអន្តរជាតិគួរអនុវត្តតាមគោលជំហររបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០២ ដែលថា "ជនណាដែលមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវបានគេហៅថា ជនត្រូវចោទ"[67] រួមទាំងដោយសារតែថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ គឺជាកម្មវត្ថុនៃ "បទចោទព្រហ្មទណ្ឌ" នៅក្នុងអត្ថន័យនៃយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស (ECHR)។ បន្ថែមពីលើនេះ មេធាវីការពារក្ដីបានលើកទឡ្ហីករណ៍ថា ដោយ

[65] បណ្ដឹងឧទ្ធរណ៍ទីពីរ, កថាខណ្ឌ ១៥-១៦។

[66] បណ្ដឹងឧទ្ធរណ៍ទីពីរ, កថាខណ្ឌ ២៨ ដល់៤១។

[67] បណ្ដឹងឧទ្ធរណ៍ទីពីរ, កថាខណ្ឌ ៣៧ និងជើងទំព័រ ៦៧។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

សារតែម្ចាស់បណ្តឹងឧទ្ធរណ៍ មានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនចាំបាច់ត្រូវការ "ភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នា" ប្រឆាំងនឹងគាត់ ដើម្បីចាត់ទុកម្ចាស់បណ្តឹងឧទ្ធរណ៍ ជាជនត្រូវចោទ និងអនុញ្ញាតឱ្យគាត់ចូល ពិនិត្យមើលសំណុំរឿងឡើយ។ ជាចុងក្រោយ មេធាវីការពារក្តីជំទាស់ថា ការអះអាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា ការចូលពិនិត្យមើលសំណុំរឿងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលមិនមែនជាភាគី អាចបង្កការប៉ះពាល់ដល់ការរក្សាការសម្ងាត់នៃកិច្ចស៊ើបសួរ គឺជាការអះអាងតាមអំពើចិត្ត ព្រោះតាមមេធាវីការពារក្តី សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្តល់សិទ្ធចូលពិនិត្យមើលសំណើរឿងរួចទៅអ្នកមិនមែនភាគីដទៃទៀត គឺអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ រួចហើយ។

26. ទីពីរ មេធាវីការពារក្តីបានលើកទឡ្ហីករណ៍ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងក្នុងការយល់ឃើញថា សិទ្ធិជាមូលដ្ឋានរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ មិនត្រូវបានរំលោភបំពាន នៅពេលដកហូតសិទ្ធិចូលពិនិត្យមើលសំណុំរឿង[68]។ មេធាវីការពារក្តីបានលើកឡើងថា ផ្ទុយទៅនឹងការអះអាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅក្នុងដីកាសម្រេចដែលរងការជំទាស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងពិតជាបានផ្តល់សំអាងហេតុ ចំពោះការអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង "ដោយបានថ្លែងយ៉ាងច្បាស់ *ក្នុងចំណោមនោះ* ថា ការចូលពិនិត្យមើលសំណុំរឿងត្រូវបានអនុញ្ញាត*អនុលោមតាមវិធាន ២១*"[69] ដែលតម្រូវឱ្យ អ.វ.ត.ក ការពារសិទ្ធិ និងផលប្រយោជន៍របស់ជនសង្ស័យ។ ការចូលពិនិត្យមើលសំណុំរឿង ធានាថា ម្ចាស់បណ្តឹងឧទ្ធរណ៍ទទួលបានការប្រព្រឹត្តិប្រហាក់ប្រហែលគ្នា ទៅនឹងអ្នកដែលត្រូវបានស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០២ ហើយមេធាវីការពារក្តីបានបញ្ជាក់ថា គឺជាការចាំបាច់ដែលឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍ ចូលរួមក្នុងកិច្ចស៊ើបសួរ។ បើយោងតាមមេធាវីការពារក្តី ភាពខុសគ្នាក្នុងការកំណត់ពេលវេលាសម្រាប់ការអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត បានធ្វើឱ្យមានអតុល្យភាពនៃលទ្ធភាពរបស់ភាគី (ដោយយោងទៅម្ចាស់បណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញា និង

[68] បណ្តឹងឧទ្ធរណ៍ទីពីរ, កថាខណ្ឌ ៤២ ដល់៥២។

[69] បណ្តឹងឧទ្ធរណ៍ទីពីរ, កថាខណ្ឌ ៤៤, យោងទៅការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង, កថាខណ្ឌ ៤។

ដើមបណ្តឹងរដ្ឋប្បវេណី) ក្នុងការបញ្ជាក់អះអាងលើរឿងក្តីរបស់ខ្លួន ដូច្នេះនេះជាការរំលោភបំពានទៅលើសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការទទួលបានសមភាពនៃគូភាគី។ មេធាវីការពារក្តីបានជំទាស់ថា ការដកហូតសិទ្ធិចូលពិនិត្យមើលសំណុំរឿងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ បានរំលោភបំពានទៅលើសិទ្ធរបស់គាត់ក្នុងការទទួលបានពេលវេលា និងមធ្យោបាយសមស្រប សម្រាប់ការរៀបចំការការពារខ្លួន ដែលត្រូវបានធានា ដូចមានចែងក្នុងមាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងដោយអនុលោមតាមយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ដែលមានន័យថា ជាការធ្វើឱ្យបុគ្គលម្នាក់ "បានដឹង និងមានយោបល់ទៅលើសេចក្តីសង្កេតនានាដែលបានដាក់ និងភស្តុតាងនានាដែលបានដាក់បន្ថែមដោយភាគីផ្សេងទៀត មុនពេលចេញសេចក្តីសម្រេចបញ្ជូនគាត់ទៅជំនុំជម្រះ ប្រសិនបើករណីនេះកើតឡើងមែននោះ"[70] ដែលទាមទារពេលវេលាបន្ថែមទៀតសម្រាប់មេធាវីការពារក្តីក្នុងសំណុំរឿង ០០៤ ជាងក្នុងសំណុំរឿង ០០២ ដោយក្នុងសំណុំរឿង ០០២ ចំនួនទីតាំងឧក្រិដ្ឋកម្មមានត្រឹមតែពាក់កណ្តាលនៃទីតាំងឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០៤ ប៉ុណ្ណោះ។

27. ទីបី មេធាវីការពារក្តីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងក្នុងការយល់ឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍ មិនមានសិទ្ធិដាក់សំណើសុំមោឃភាព អនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង[71]។ មេធាវីការពារក្តីបន្តអះអាងថា ម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលជាកម្មវត្ថុនៃការចោទប្រកាន់ ត្រូវទទួលបានសិទ្ធិជាភាគីនៃកិច្ចដំណើរការនីតិវិធី។

## III. មតិយោបល់ និងសេចក្តីសន្និដ្ឋាន

28. មេធាវីការពារក្តីបានលើកទឡ្ហីករណ៍ថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន ដោយផ្អែកទៅលើវិធាន ២១ នៃវិធានផ្ទៃក្នុងតែមួយ ព្រោះសិទ្ធិជាសារវន្តរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ តម្លាភាពនៃកិច្ចដំណើរការនីតិវិធី សមភាពនៃគូភាគី និងការទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ក្នុងការរៀបចំការការពារខ្លួនរបស់គាត់ នឹងត្រូវទទួលរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ប្រសិនបើពុំមានសិទ្ធិប្តឹងឧទ្ធរណ៍នោះ។ មេធាវីការពារក្តីបានស្នើឡើងថា ដោយសារតែវិធាន ២១ នៃវិធានផ្ទៃក្នុង អាចអនុវត្តផងដែរចំពោះជនសង្ស័យនោះ អង្គបុរេជំនុំជម្រះអាច

[70] បណ្តឹងឧទ្ធរណ៍ទីពីរ, កថាខណ្ឌ ៥០។

[71] បណ្តឹងឧទ្ធរណ៍ទីពីរ, កថាខណ្ឌ ៥៣ ដល់៥៦។

អនុម័តយកការបកស្រាយក្នុងន័យទូលាយទៅលើសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ដើម្បីធានាថាសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនសង្ស័យ ត្រូវបានការពារក្នុងលក្ខណៈប្រហាក់ប្រហែលគ្នាដូចដែលអង្គជំនុំជម្រះធ្លាប់បានអនុវត្តកន្លងមក ទាក់ទិនទៅនឹងសិទ្ធិរបស់ជនត្រូវចោទដែរ។ ផលប្រយោជន៍សំខាន់បំផុតដែលម្ចាស់បណ្តឹងឧទ្ធរណ៍ចង់បានតាមរយៈបណ្តឹងឧទ្ធរណ៍នោះ គឺសិទ្ធិចូលពិនិត្យមើលសំណុំរឿងទាំងមូលក្នុងសំណុំរឿង ០០៤ ការអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចស៊ើបសួរ និងការអនុញ្ញាតឱ្យធ្វើសំណើសុំមោឃភាព អនុលោមតាមវិធានផ្ទៃក្នុង។ បញ្ហាសំខាន់នៅក្នុងបណ្តឹងឧទ្ធរណ៍គឺថាតើ ម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលជាជនសង្ស័យម្នាក់មានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទទួលបានសិទ្ធិទាំងនេះនៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី ដែរឬទេ។ ដីកាសម្រេចដែលរងការជំទាស់ រារាំងម្ចាស់បណ្តឹងឧទ្ធរណ៍មិនឱ្យមានសិទ្ធិទាំងនេះ រហូតដល់គាត់ត្រូវបានចោទប្រកាន់ជាផ្លូវការ។

29. មានការយោងទៅលើវិធាន ៤៨, ៥៥(១០) និង ៧៦ នៃវិធានផ្ទៃក្នុង ដែលចែងអំពីនីតិវិធី ដែលយកមកអនុវត្តចំពោះការដាក់សំណើសុំស៊ើបអង្កេត និងសំណើសុំមោឃភាព។ មានការយោងផងដែរទៅលើវិធាន ៥៥(៦) នៃវិធានផ្ទៃក្នុង ដែលចែងអំពីនីតិវិធី ដែលយកមកអនុវត្តចំពោះសិទ្ធិចូលពិនិត្យមើលសំណុំរឿង។ វិធាននីមួយៗក្នុងចំណោមវិធានទាំងនេះ ដែលពិពណ៌នាអំពីសិទ្ធិផ្នែកនីតិវិធី យោងយ៉ាងច្បាស់ទៅលើពាក្យ"ជនត្រូវចោទ" មិនមែនយោងទៅលើពាក្យ"ជនសង្ស័យ"ឡើយ។ ជាបន្តបន្ទាប់មកទៀត វិធាន ៧៣ និង ៧៤ នៃវិធានផ្ទៃក្នុង ដែលចែងអំពីយុត្តាធិការរបស់អង្គបុរេជំនុំជម្រះក្នុងការសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬពាក្យសុំនានា ទាក់ទិននឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលបដិសេធសំណើសុំស៊ើបអង្កេត ឬសំណើសុំមោឃភាព ក៏យោងយ៉ាងច្បាស់ផងដែរទៅលើពាក្យ "ជនត្រូវចោទ" មិនមែនយោងទៅលើពាក្យ "ជនសង្ស័យ"ឡើយ។ ចុងក្រោយ មានការយោងទៅលើវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលចែងអំពីគោលការណ៍ជាសារវន្តសម្រាប់នីតិវិធីដែលយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក។

30. អង្គបុរេជំនុំជម្រះបានសម្រេចកាលពីមុនថា គោលការណ៍ជាសារវន្តដែលមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលឆ្លុះបញ្ចាំងនូវលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ដែល អ.វ.ត.ក មានកាតព្វកិច្ចត្រូវអនុវត្ត អនុលោមតាមមាត្រា ១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការ

សហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា[72], មាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក[73] និង មាត្រា ១៤(៣) នៃ ICCPR[74] អាចតម្រូវឱ្យអង្គបុរេជំនុំជម្រះធ្វើការបកស្រាយសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ក្នុងន័យទូលាយ ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីមានភាពយុត្តិធម៌ និងបានគោរពគោលការណ៍ចំពោះមុខ ហើយបានរក្សានូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ[75]។ នៅពេលដែលអង្គហេតុ និងកាលៈទេសៈពិសេសនៃរឿងក្តីតម្រូវនោះ អង្គបុរេជំនុំជម្រះបានទទួលយក

---

[72] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣។

[73] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុង រយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ បូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")។

[74] *សូមមើល ឧទាហរណ៍* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០២") (អបជ៦៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ A371/2/12 កថាខណ្ឌ ១៣-១៨, ២៧ ("វាប្រាកដណាស់ថា មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានចែងថា ជនដែលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន មានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយរួមទាំងសិទ្ធិទទួលបានពេលវេលា និងសម្ភារគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន [...]។ អានុភាពអនុវត្តរបស់មាត្រា ១៣ នៃកិច្ចព្រមព្រៀង និងមាត្រា ៣៥ថ្មី នៃច្បាប់ស្តីពី អ.វ.ត.ក បានផ្តល់ការណែនាំជាក់លាក់ឱ្យអង្គបុរេជំនុំជម្រះពិចារណាមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ ក្នុងករណីនេះ ដោយមិនគិតពីវិធាន ២១ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះត្រូវតែពិនិត្យថាតើ ដីកាដែលរងការជំទាស់នេះ បានបំពានលើសិទ្ធិទាំងឡាយរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលបានការពារដោយមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែរឬទេ")។

[75] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២ (អបជ១១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ទាក់ទងនឹងការបកប្រែ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារ A190/I/20 កថាខណ្ឌ ៣៦។ សំណុំរឿង ០០២ (អបជ៧១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D390/1/2/4 ("សាលដីកាស្តីពីចម្លើយតបរបស់ អៀង សារី") កថាខណ្ឌ ១៣។ សំណុំរឿង ០០២ (អបជ១៤) សាលដីកាលើការជូនដំណឹងរបស់មេធាវីការពារក្តីអំពីការបកប្រែមានកំហុសឆ្គង ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារលេខ ២ ("សាលដីកាស្តីពីកំហុសឆ្គងក្នុងការបកប្រែ") កថាខណ្ឌ ៣។ សំណុំរឿង ០០២ (អបជ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៩។

បណ្តឹងឧទ្ធរណ៍ដែលលើកឡើងអំពីបញ្ហានៃសិទ្ធិជាសារវ័ន្ត ឬ "បញ្ហាធ្ងន់ធ្ងរនៃភាពយុត្តិធម៌" ដោយធ្វើការបកស្រាយបទប្បញ្ញត្តិជាក់លាក់ក្នុងន័យទូលំទូលាយ ដែលផ្តល់សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍[76] ឬដោយសន្មតយុត្តាធិការទៅលើបណ្តឹងឧទ្ធរណ៍ ដែលមិនស្ថិតនៅក្នុងយុត្តាធិការច្បាស់លាស់របស់អង្គជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាននៃវិធាន ២១ នៃវិធានផ្ទៃក្នុង[77]។

31. អង្គបុរេជំនុំជម្រះ មានការខ្វែងយោបល់គ្នាទៅលើបញ្ហាថាតើ ម្ចាស់បណ្តឹងឧទ្ធរណ៍មានសិទ្ធិដាក់បណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៤ និង ៧៦ នៃវិធានផ្ទៃក្នុង ដែរឬទេ ដោយសារថាគាត់មិនទាន់ត្រូវបានជូនដំណឹងជាផ្លូវការអំពីបទចោទប្រឆាំងនឹងរូបគាត់ អនុលោមតាមនីតិវិធីដែលមានចែងនៅក្នុងវិធាន ៥៧ នៃវិធានផ្ទៃក្នុង។ ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ហួត វុទ្ធី និងចៅក្រម ន័យ ធុល យល់ឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលមិនមែនជា "ជនត្រូវចោទ" ហើយក៏មិនមែនជា "ជនជាប់ចោទ" អនុលោមតាមវិធានផ្ទៃក្នុង មិនអាចដាក់បណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៤ និង ៧៦ នៃវិធានផ្ទៃក្នុងបានទេ។ ផ្ទុយទៅវិញ ចៅក្រម CHUNG និងចៅក្រម DOWNING ដែលធ្វើការបកស្រាយខុសគ្នាទៅលើវិធាន ៧៤ និង ៧៦ នៃវិធានផ្ទៃក្នុង ដោយពិចារណាលើវិធាន ២១ នៃវិធានផ្ទៃក្នុង យល់ឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍មានសិទ្ធិដាក់បណ្តឹងឧទ្ធរណ៍ទាំងនេះ ដោយសារថាអ្វីដែលជាបញ្ហាប្រឈមជាក់លាក់នោះ គឺការបកស្រាយសញ្ញាណនៃ "ជនត្រូវចោទ" ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចនៅក្នុងដីកាសម្រេចដែលរងការជំទាស់ និងយល់ឃើញថា នៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី សិទ្ធិជាមូលដ្ឋានរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌តម្រូវថា គាត់គួរទទួលបានសិទ្ធិផ្នែកនីតិវិធីដូចគ្នាទៅនឹងសិទ្ធិទាំងឡាយដែលផ្តល់ឲ្យជនត្រូវចោទដែរ។ ចៅក្រមនៃអង្គបុរេជំនុំជម្រះ នៅតែមានការខ្វែងយោបល់គ្នា និងប្រកាន់យកការបកស្រាយរៀងៗខ្លួនទៅលើ

---

[76] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២ (អបជ០៥) សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អំពីសិទ្ធិចូលជួប ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៨ ឯកសារ A104/II/4 កថាខណ្ឌ ១០។

[77] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២ (អបជ៤២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំឲ្យរកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ ឯកសារ D264/2/6 កថាខណ្ឌ ១៣-១៤។ សាលដីកាស្តីពីចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ១៣ និង សាលដីកាស្តីពីកំហុសឆ្គងក្នុងការបកប្រែ កថាខណ្ឌ ២-៦។

បញ្ហានេះ ដែលជាផ្នែកដ៏សំខាន់បំផុតនៃបណ្តឹងឧទ្ធរណ៍ទាំងនេះ[78]។ ទោះបីជាមានការខិតខំប្រឹងប្រែងរបស់អង្គបុរេជំនុំជម្រះយ៉ាងណាក៏ដោយ ក៏អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រភាគច្រើនបួនសំឡេងតាមការកំណត់ ដើម្បីឈានទៅដល់ការធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បានឡើយ។

32. ដោយសារតែអង្គបុរេជំនុំជម្រះមិនអាចធ្វើសេចក្តីសម្រេចទៅលើបណ្តឹងឧទ្ធរណ៍នេះបាន វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង កំណត់ថា ដីកាសម្រេចដែលរងការជំទាស់នោះ ត្រូវតម្កល់ទុកជាបានការ។

## IV. ផ្នែកសម្រេចសេចក្តី

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេច ៖**

**ប្រកាសជាឯកច្ឆន្ទ ថា** អង្គបុរេជំនុំជម្រះមិនអាចរកបានសំឡេងគាំទ្រពីចៅក្រម យ៉ាងតិចបួនសំឡេង ដើម្បីធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍នេះបានឡើយ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Rowan DOWNING** **ន័យ ថុល** **Chang-ho CHUNG** **ហួត វុទ្ធី**

[78] ចំពោះសេចក្តីលម្អិតនៃមតិយោបល់ និងការបកស្រាយខុសគ្នារបស់អង្គបុរេជំនុំជម្រះលើបញ្ហានេះ សូមមើល៖ ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធលើសំណើសុំពិនិត្យមើលឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត ឯកសារ D121/4/1/4 ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ ដែលអាចរកមើលបានជាសាធារណៈ។